FROM PRIMARY TO HIGH SCHOOL: THE NEXT BIG STEP
HOW PARENTS CAN HELP
INFORMATION SHEET 2

# ចាប់ពីសាលាបឋមសិក្សា ទៅសាលាមធ្យមសិក្សា៖ ជំហានធំបន្ទាប់ទៀត

## របៀបដែលមាតាបិតាអាចជួយ







ការចូលរៀននៅសាលាមធ្យមសិក្សា គឺជាបទពិសោធន៍ថ្មីមួយសំរាប់កូនរបស់លោកអ្នក។ សាលារៀនទំនងជាមានកូនសិស្សច្រើន ហើយកូនរបស់លោកអ្នកនឹងមានគ្រូបង្រៀនខុសគ្នា ថ្នាក់រៀនខុសគ្នា ហើយនឹងត្រូវការយកជាប់ជាមួយនូវការកត់សំគាល់ និងសៀវភៅពីថ្នាក់រៀនមួយ ទៅថ្នាក់រៀនមួយទៀត។

មុនកូនរបស់លោកអ្នកចាប់ផ្តើមចូលរៀនសាលាមធ្យមសិក្សា សូមនិយាយប្រាប់គេឲ្យបានដឹងជាមុនអំពីសភាពការ និងមនុស្សទាំងឡាយដែលគេអាចជួបប្រទះនៅសាលារៀន ហើយជួយលើកទឹកចិត្តគេឲ្យឆ្លៀតឱកាសបង្កើតមិត្តភក្តិថ្មីៗ។

ដោយមានជំនួយពីគ្រួសារ និងបុគ្គលិកសាលា ជាញឹកញយសិស្សសម្របសម្រួលបានភ្លាមៗទៅនឹងសភាពការថ្មីរបស់គេ។

**សូមកត់សំគាល់៖**

នេះគឺជាការសំខាន់ចាំបាច់ដែលលោកអ្នកត្រូវប្រាប់នាយកសាលា មុនសាលារៀនចាប់ផ្តើម ប្រសិនបើកូនរបស់លោកអ្នកមានប្រតិកម្មទាស់នឹងធាតុអ្វីមួយ ឬមានបញ្ហាសុខភាពណាមួយ។ លោកអ្នកអាចប្រាប់អំពីការនេះ នៅក្នុងពាក្យបំពេញសុំចុះឈ្មោះចូលរៀន នៅត្រង់កន្លែងដែលមានផ្តល់។

លោកអ្នកក៏ត្រូវផ្តល់ដំណឹងទៅសាលារៀនឲ្យបានភ្លាមផងដែរ កាលណាលោកអ្នកបានដឹងអំពីប្រតិកម្មទាស់នឹងធាតុអ្វីមួយ ឬបញ្ហាសុខភាពថ្មីណាមួយ។

### គ្រូបង្រៀនថ្មី

នៅសាលាមធ្យមសិក្សា សិស្សអាចមានគ្រូបង្រៀនចំនួន៨នាក់ ឬច្រើនជាង ព្រមទាំងអ្នកប្រឹក្សាសិស្ស ដើម្បីផ្តល់ជំនួយ និងការគាំទ្រ។ នេះគឺជាការធម្មតាទេដែលសិស្ស Year 7 ថ្មី មានអារម្មណ៍ខ្វល់ព្រួយអំពីរឿងនេះ។

នេះគឺជាកិច្ចការសំខាន់ដែលត្រូវប្រាប់គេឲ្យបានដឹងថាមានមនុស្សរង់ចាំជួយគេ ហើយគេមិនត្រូវរួញរាក្នុងការសួរសំណួរទេ។

### តារាងពេលវេលា

មុខវិជ្ជានៅសាលាមធ្យមសិក្សា ជាធម្មតាត្រូវបានបង្រៀនក្នុងមេរៀន៤០នាទី ទៅ៦០នាទីដែលហៅថា 'periods' ម៉ោង ឬលើក'។ មុខវិជ្ជានីមួយៗនឹងត្រូវបង្រៀនមួយ ឬពីរ periods ក្នុងមួយដងៗ។ ដើម្បីតាមមើលនូវគ្រប់ទាំងមេរៀន និងថ្នាក់រៀនរបស់គេ កូនរបស់លោកអ្នកនឹងទទួលតារាងពេលវេលាដែលបង្ហាញប្រាប់ពីមុខវិជ្ជា period បង្រៀន និងទីកន្លែងបន្ទប់រៀន។

នេះគឺជាការល្អដែលជួយកូនរបស់លោកអ្នកឲ្យឆែកមើលតារាងពេលវេលា កាលគេមកដល់ផ្ទះរៀងរាល់ល្ងាច ធ្វើដូច្នេះឲ្យគេអាចរៀបចំកាបូបស្ពាយរបស់គេ ឲ្យមានគ្រប់ទាំងអ្វីៗគ្រប់គ្រាន់ដែលគេនឹងត្រូវការសំរាប់ថ្ងៃបន្ទាប់ – ដូចជាសៀវភៅ សម្ភារៈសរសេរ ឯកសណ្ឋានកីឡា PE និងសម្ភារៈកីឡា។

### មិត្តភក្តិថ្មី

ការបង្កើតមិត្តភក្តិថ្មី ប្រហែលជាកិច្ចការមួយដ៏សំខាន់ជាងគេ ដែលកូនរបស់លោកអ្នកនឹងជួបប្រទះនៅពេលគេចាប់ផ្តើមចូលរៀន Year 7។ សូមលើកទឹកចិត្តកូនរបស់លោកអ្នកឲ្យចូលរួមនៅក្នុងសកម្មភាពនានា ដើម្បីឲ្យគេអាចស្គាល់សិស្សឯទៀត ហើយមានពេលសប្បាយជាមួយគ្នា។

### ការចូលរួមពីមាតាបិតា

សាលាមធ្យមសិក្សារបស់យើងសូមស្វាគមន៍ចំពោះការចូលរួម និងការធ្វើវិភាគទានពីមាតាបិតា។

ក្រុមមាតាបិតាដូចជា P&C Association (សមាគមន៍របស់មាតាបិតា និងពលរដ្ឋ) ផ្តល់នូវឱកាសឲ្យចូលរួមនៅក្នុងជីវិតសាលារៀន ហើយចូលរួមនៅក្នុងការធ្វើសេចក្តីសំរេច។ ការស្ម័គ្រចិត្តសំរាប់ពិធីផ្សេងៗ និងនៅក្នុងថ្នាក់រៀនអាចជាផ្លូវមួយល្អដើម្បីជួបជាមួយមាតាបិតា និងបុគ្គលិកសាលាឯទៀត។ យើងឲ្យតម្លៃចំពោះជំនួយណាមួយដែលលោកអ្នកអាចផ្តល់។

NEW SOUTH WALES
DEPARTMENT OF EDUCATION AND TRAINING

## ជំនួយសំរាប់សិស្សដែលមានសេចក្តីត្រូវការពិសេស

ក្នុងភាពជាមាតាបិតា ឬអ្នកមើលថែក្មេងដែលមានពិការភាព ឬការលំបាកក្នុងការសិក្សា លោកអ្នកនឹងបានទទួលជំនួយពីមនុស្សមួយចំនួន ដែលនឹងធ្វើការជាមួយលោកអ្នក ដើម្បីជួយលោកអ្នកឲ្យធ្វើជំរើសត្រឹមត្រូវសំរាប់កូនរបស់លោកអ្នក។

ជំរើសដែលមានសំរាប់សាលាមធ្យមសិក្សាមានរួមទាំង:

- ថ្នាក់រៀនធម្មតា នៅសាលារៀនធម្មតា
- ថ្នាក់រៀនជំនួយ នៅសាលារៀនធម្មតា
- សាលារៀនដែលមានកិច្ចបំរើគាំទ្រពិសេស។

មុនការចុះឈ្មោះកូនរបស់លោកអ្នក លោកអ្នកនឹងត្រូវគេស្នើសុំឲ្យទាក់ទងជាមួយការិយាល័យប្រចាំតំបន់លោកអ្នក ដើម្បីឲ្យបុគ្គលិករបស់យើងអាចប៉ាន់ស្មង់លើជំរើសរបស់លោកអ្នក ហើយជួយលោកអ្នកជ្រើសរើសសាលារៀនត្រឹមត្រូវសំរាប់កូនរបស់លោកអ្នក។

## ឯកសណ្ឋានសាលា និងឯកសណ្ឋានសាលាសំរាប់លក់

ការឲ្យកូនរបស់លោកអ្នកស្លៀកពាក់ឯកសណ្ឋានសាលាត្រឹមត្រូវនៅថ្ងៃទីមួយ នឹងជួយគេឲ្យមានអារម្មណ៍ថាគេជាសិស្សនៅសាលារៀនថ្មីនេះ។ ជាញឹកញាយសាលារៀនរៀបចំ school clothing pool (ឯកសណ្ឋានសំរាប់លក់នៅសាលារៀន) ឬសាលារៀនអាចជំរាបលោកអ្នក អំពីហាងលក់មួយណាដែលលក់ឯកសណ្ឋានសិស្ស។

## ប័ណ្ណធ្វើដំណើរ

ពាក្យបំពេញសំរាប់ប័ណ្ណរថភ្លើង រថយន្តបាស់ និង/ឬសាឡាង នឹងអាចរកបានពីសាលាមធ្យមសិក្សារបស់កូនលោកអ្នកនៅត្រីមាសទី៤។ ពាក្យបំពេញទាំងនេះ ជាញឹកញាយត្រូវបានផ្ញើទៅលោកអ្នកជាមួយនឹងពាក្យបំពេញសុំចុះឈ្មោះចូលរៀន។ លោកអ្នកត្រូវបញ្ជូនពាក្យនេះ ទៅសាលាមធ្យមសិក្សាវិញឲ្យបានមុនចុងឆ្នាំសិក្សា ដើម្បីធ្វើយ៉ាងណាឲ្យសិស្សមានប័ណ្ណសំរាប់ការចាប់ផ្តើមឆ្នាំសិក្សាបន្ទាប់។

ក្រសួងដឹកជញ្ជូនចាត់ចែងនូវគំរោងការដឹកជញ្ជូនសិស្សសាលា។ ប្រសិនបើលោកអ្នកមានចម្ងល់បន្ថែមទៀត សូមទូរស័ព្ទទៅក្រសួងដឹកជញ្ជូនលេខ 1800 227 774 ឬ (02) 9891 8900។

## ការធ្វើវិភាគទានដល់សាលារៀន និងការចំណាយលើការសិក្សា

សាលាមធ្យមសិក្សារដ្ឋមានការចំណាយពីរប្រភេទ។ ការវិភាគទានដោយស្ម័គ្រចិត្តទូទៅ ត្រូវបានស្នើសុំឲ្យជួយសាលារៀនដើម្បីផ្តល់ធនធាន និងឱកាសសំរាប់ការសិក្សាដល់ពួកសិស្ស។

ក៏មានថ្លៃឈ្នួលលើមុខវិជ្ជាផងដែរ ដែលត្រូវបានស្នើសុំសំរាប់មុខវិជ្ជាជាក់លាក់មួយចំនួន ដូចជាបច្ចេកវិទ្យាខាងម្ហូបចំណី និងសិល្បៈរូបភាព។ ថ្លៃឈ្នួលលើមុខវិជ្ជា ជួយបង់ថ្លៃសម្ភារៈដែលកូនរបស់លោកអ្នកប្រើនៅក្នុងកម្មវិធីសិក្សានីមួយៗទាំងនេះ។

ប្រសិនបើលោកអ្នកជួបប្រទះនឹងការលំបាកផ្នែកប្រាក់កាស សូមពិគ្រោះជាមួយនាយកសាលារបស់លោកអ្នក។ សាលារៀនអាចផ្តល់នូវជំនួយលើថ្លៃឈ្នួលមុខវិជ្ជា និងការចំណាយដទៃទៀតដូចជាឯកសណ្ឋានសាលា ដំណើរសិក្សាសាលា និងការបោះជំរំសាលា។

## ទូរស័ព្ទដៃ

ការប្រើទូរស័ព្ទដៃ និងគ្រឿងទំនាក់ទំនងអេឡិចត្រូនិចដទៃទៀតនៅក្នុងម៉ោងសាលា មិនបានលើកទឹកចិត្តឲ្យមានជាដាច់ខាតនៅសាលារៀនរបស់យើង ហើយជាប្រាកដណាស់ សិស្សមិនអាចប្រើទូរស័ព្ទក្នុងម៉ោងរៀនឡើយ។ មាតាបិតាត្រូវបានស្នើសុំឲ្យចៀសវាងទូរស័ព្ទ ឬផ្ញើដំណឹងតាម SMS ទៅកូនរបស់ខ្លួនក្នុងម៉ោងរៀន ប្រសិនបើអាចធ្វើទៅបាន។ ប្រសិនបើចាំបាច់ លោកអ្នកអាចផ្តាំផ្ញើដំណឹងទៅសិស្សតាមរយៈការិយាល័យសាលា។

## កិច្ចបំរើអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា ដើម្បីជួយលោកអ្នកទាក់ទងជាមួយនាយកសាលា សូមទូរស័ព្ទទៅកិច្ចបំរើអ្នកបកប្រែភាសាលេខ 131 450 ហើយស្នើសុំអ្នកបកប្រែភាសាជាភាសារបស់លោកអ្នក។ នៅពេលនោះអ្នកបកប្រែភាសានឹងទូរស័ព្ទទៅនាយកសាលា ហើយនិងជួយលោកអ្នកក្នុងការសន្ទនាតាមទូរស័ព្ទ។ លោកអ្នកនឹងមិនបង់ថ្លៃសំរាប់កិច្ចបំរើនេះទេ។

© May 2006
NSW Department of Education and Training

GPO Box 33
Sydney NSW 2001
T 9561 8000
www.det.nsw.edu.au
NSW Public Schools - Leading the way
សាលារៀនរដ្ឋញូវសៅវែល – ជាអ្នកនាំផ្លូវ

NEW SOUTH WALES DEPARTMENT OF EDUCATION AND TRAINING

## ចង់ដឹងបន្ថែមទៀត ?

ចំពោះព័ត៌មានបន្ថែមទៀត សូមនិយាយជាមួយនាយកសាលារបស់លោកអ្នក ទាក់ទងជាមួយការិយាល័យប្រចាំតំបន់របស់លោកអ្នក ឬបើកមើលនៅត្រង់គេហទំព័រ www.schools.nsw.edu.au

ដើម្បីទទួលយកពត៌មានដែលបកប្រែរួច សូមបើកមើលនៅត្រង់គេហទំព័រ www.det.nsw.edu.au/languagesupport

KHMER